**តុលាការខេត្តបាត់ដំបង**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៧៥៥ ចុះថ្ងៃទី ០៦
ខែ តុលា ឆ្នាំ ២០០៥
**សាលក្រម**
លេខ ៣៤ ក ចុះថ្ងៃទី ១៧
ខែ កុម្ភៈ ឆ្នាំ ២០០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តបាត់ដំបង**

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៧៥៥ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ ឃ ចរ ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីស្រីខារ៉ាអូខេ មានទីកន្លែងកំណើតនៅខេត្តសៀមរាប មានកំរិតវប្បធម៌ថ្នាក់ទី ២ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលីវ មានឪពុកឈ្មោះ ឃ ឃ (រ) មានម្តាយឈ្មោះ ឡ ម (រ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ០១ឆ្នាំ ពីបទចោរកម្មតាមអំណាចសាលក្រមព្រហ្មទណ្ឌរបស់តុលាការខេត្តបាត់ដំបង ។

ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៥ នៅចំណុចមុខរោងចក្រក្រចៅ ភូមិព្រៃកតាច្រេង ឃុំព្រែកនរិទ្ធ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ហើយត្រូវបានឃុំខ្លួន តាមដីកាលេខ ៤៦២ ដឃខ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៥ នៅអាគារឃុំខ្លួននៃពន្ធនាគារខេត្តបាត់ដំបង ។

ត្រូវចោទពីបទ <u>ចោរកម្ម</u> ។ តាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ ប្រព្រឹត្តនៅភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ ។

**ជនរងគ្រោះ**

ឈ្មោះ ឌ ល ហៅ ស ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ របររកស៊ីរត់ម៉ូតូឌុប ទីលំនៅភូមិបែកចានថ្មី ឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ប្តឹងសុំអោយសមត្ថកិច្ចផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ ឈ្មោះ យ ចរ បានចូលវត្តកណ្តាល ពេលនោះខ្លួនឃើញម៉ូតូគេចតទុក ក៏ឡើងជិះបើកចេញទៅតែម្តង ។

-តាមរបាយការណ៍លេខ ២២០ រប.រតនៈ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៥ របស់ប៉ុស្តិ៍នគរបាលឃុំរតនៈបាន បញ្ជាក់ថា កាលពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ១៩ និង ៣០នាទី នៅចំណុចវត្តកណ្តាល ភូមិរំចេក៤ ឃុំរតនៈ មានជនល្មើសឈ្មោះ ៖ អាយុប្រហែល ២០ឆ្នាំ បានខ្ចីម៉ូតូរបស់ឈ្មោះ ឳ ល ភេទប្រុសយកទៅបាត់តែម្តង ។

## នៅចំពោះមុខនាពេលសវនាការ

-ឈ្មោះ យ ចរ ជាជនជាប់ចោទបានឆ្លើយថា ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ១៩ ខ្លួនពិតជាបាន យកម៉ូតូរបស់គេពិតប្រាកដមែន ។ ម៉ូតូខ្លួនយកនោះម៉ាកសេ ១២៥ ពណ៌ខ្មៅ ស៊េរី២០០៣ ។ កន្លងមក ខ្លួនធ្លាប់ត្រូវបាន តុលាការកាត់ទោសម្តងហើយ ។

-ឈ្មោះ ឳ ល ជាជនរងគ្រោះតាមការអានចម្លើយបានឆ្លើយថា ( មើលឯកសារលេខ ០១ ) ។

-តាមការអានចម្លើយឈ្មោះ ស សរ ជាសាក្សីបានឆ្លើយថា ( មើលឯកសារលេខ ០៣ ) ។

## តំណាងអយ្យការបានធ្វើសន្និដ្ឋានថា

ស្នើសុំតម្កល់បទចោទទុកជាបានការពេញទាំងមូលដដែល និង សុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ

-បានស្តាប់ក្រឡាបញ្ជីអានចម្លើយអោយការណ៍របស់ជនរងគ្រោះ ចម្លើយសាក្សី

-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់

-បានពិនិត្យ កំណត់ហេតុ ឯកសារ ភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិចារណាត្រឹមត្រូវហើយ

## តុលាការខេត្តបាត់ដំបង

## យល់ឃើញថា

-ពិតជាកើតមាននូវអំពើចោរកម្មនៅភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើចោរកម្មដែលកើតនៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ យ ចរ លួចយកម៉ូតូរបស់ឈ្មោះ ឳ ល ប្រាកដមែន ។

-អំពើដែលឈ្មោះ យ ចរ បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់ ជាបទចោរកម្ម ដូចមានបញ្ញត្តិក្នុងមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ឈ្មោះ យ ចរ ជាសមត្ថជន គាត់មានអាយុ ២២ឆ្នាំ មានស្មារតីជានាល្អ គាត់បានលូកដៃប្រព្រឹត្តបទល្មើស ដោយចេតនាលបលួចយក ម៉ូតូជាទ្រព្យរបស់ឈ្មោះ ឳ ល ដែលទុកក្នុងវត្តកណ្តាល បំណងយកទៅបំរើផលប្រយោជន៍សួនតួ

បុគ្គលបានសំរេច ដោយបានជិះចេញផុតពីកន្លែងដែលម្ចាស់របស់ទុក ទើបត្រូវសមត្ថកិច្ចចាប់ខ្លួនបានដោយម៉ូតូអស់សាំង ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ យ ច៖ ពីបទចោរកម្ម ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយដោះសាររបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ អំពើដែលខ្លួនបានប្រព្រឹត្ត ហើយវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយអោយការណ៍របស់សាក្សី និង ចម្លើយជនរងគ្រោះ ។ ឯចម្លើយដោះសាររបស់ជនជាប់ចោទថា ខ្លួនមិនមានបំណងលួចយកម៉ូតូរបស់គេនោះគ្មានភស្តុតាងណាមកបញ្ជាក់ទេ វាខុសនឹងសកម្មភាពនៃអំពើដែលខ្លួនបានប្រព្រឹត្ត ។

-ឈ្មោះ ឲ ល ជាជនរងគ្រោះបានឆ្លើយអោយការយ៉ាងច្បាស់លាស់ថា នៅយប់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោងប្រហែល ១៩ ខ្លួនបានជិះម៉ូតូទៅលេងឈ្មោះ គ និង ព្រះសង្ឃព្រះនាម ព នៅវត្តកណ្តាល អង្គុយលេងប្រហែល ២០នាទី ខ្លួនជិះម៉ូតូត្រឡប់មកផ្ទះវិញ បានបុកនឹងគល់ដូង ម៉ូតូក៏ដួលខណៈពេលនោះស្រាប់តែនារីឈ្មោះ រ បានដើរមកដល់ឡើងជិះម៉ូតូរបស់ខ្លួនរួចបើកចេញទៅបាត់ចម្លើយនេះវាស៊ីសង្វាក់នឹងចម្លើយរបស់ជនជាប់ចោទ និង សាក្សីឈ្មោះ ស ស៖ និង ហេតុការណ៍កាលៈទេសៈប្រព្រឹត្តបទល្មើស ។

-សាក្សីឈ្មោះ ស ស៖ បានឆ្លើយអោយការណ៍ថា នៅវេលាយប់ម៉ោងប្រហែល ១៩ និង ៣០នាទី ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ ខ្លួនកំពុងអង្គុយលេងនៅកុដិលេខ ១០ វត្តកណ្តាលជាមួយឈ្មោះ ឲ ល អង្គុយលេងប្រហែល ១៥នាទី ឈ្មោះ ឲ ល ក៏ជិះម៉ូតូទៅផ្ទះបានបុកនឹងគល់ដូងក៏ដួលម៉ូតូ ខ្លួនក៏ដើរទៅមើលពេលនោះខ្លួនបានឃើញឈ្មោះ រ ដើរមកដល់ឡើងជិះម៉ូតូរបស់ឈ្មោះ ឲ ល បើកចេញទៅបាត់ ។

-កំណត់ហេតុ ឯកសារ ភស្តុតាងនានា ធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

-កំណត់ហេតុដកហូតវត្ថុតាងពីជនជាប់ចោទ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៥ ធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ស្រុកឯកភ្នំ ។

## យល់ឃើញថា

-ឈ្មោះ យ ច៖ ជាជនមានជីវភាពក្រខ្សត់ គាត់ពុំដែលមានទោសពីមុនមក ការប្រព្រឹត្តរបស់គាត់បានសំរេច តែមិនបានអាស្រ័យផល ដោយម្ចាស់ទ្រព្យបានយកទ្រព្យរបស់គេទៅវិញ ហើយស្ថានភាពទាំងនេះអាចអោយតុលាការយកមកពិចារណាជាស្ថានសម្រាលទោសអោយគាត់បាន ។

-វត្ថុតាងជាកម្មវត្ថុនៃបទល្មើសមានតម្លៃខ្ពស់បង្ហូរជនជាប់ចោទបានប្រព្រឹត្តបទល្មើសក្នុងករណីមិនរាងចាលជាហេតុតុលាការយកមកពិចារណាជាស្ថានទម្ងន់ទោស ។

-ជនជាប់ចោទធ្លាប់បានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ដោយដាក់ពន្ធនាគារ ០៣ខែ និង ១៥ថ្ងៃ ០៨ខែ និង ១៥ថ្ងៃ អោយគាត់ទទួលទោសព្យួរកំណត់រយៈពេលសាកល្បង ០៥ឆ្នាំ ចាប់ពី

ក្រោយពេលកាត់សេចក្តីក្នុងរយៈពេលសាកល្បង គាត់បានប្រព្រឹត្តអំពើចោរកម្មមួយទៀត ដែលតុលាការត្រូវយកមកបូកនឹងទណ្ឌកម្មក្នុងការសំរេចទណ្ឌកម្ម ។

**ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសឈ្មោះ យ ចរ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ ០៣ខែ និង ១៥ថ្ងៃគត់ ។

ពីបទ ចោរកម្ម ប្រព្រឹត្តនៅភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ បូកបន្ថែមទណ្ឌកម្ម ០៨ខែ និង ១៥ថ្ងៃ ដែលព្យួរទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤៩ "ក" ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ របស់តុលាការខេត្តបាត់ដំបង ។

ទណ្ឌកម្មសរុបកំណត់ ០៣ឆ្នាំគត់ ដោយគិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ០៩៩២ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]

---

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រមអោយសំរេចតាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្តអោយបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង.ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*
**ជ.ក្រឡាបញ្ជីសវនាការ**
[redacted]

**បានឃើញ**
*បាត់ដំបង.ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*
**ប្រធានតុលាការខេត្ត**
[redacted]